# សិទ្ធិរបស់អ្នកជាអ្នកបង់ពន្ធ

ការបោះពុម្ពផ្សាយលេខ១

ការបោះពុម្ពផ្សាយនេះ ពន្យល់អំពីសិទ្ធិរបស់អ្នកជាអ្នកបង់ពន្ធ និងដំណើរការសម្រាប់ការពិនិត្យ ការប្តឹងឧទ្ធរណ៍ ការប្រមូលពន្ធ និងប្រាក់បង្វិលសងវិញ។

## សិទ្ធិរបស់អ្នកបង់ពន្ធ

### ១. សិទ្ធិទទួលបានការជូនព័ត៌មាន

អ្នកបង់ពន្ធមានសិទ្ធិដើម្បីដឹងពីអ្វីដែលពួកគេត្រូវបំពេញដើម្បីអនុវត្តតាមច្បាប់ពន្ធដារ។ ពួកគេមានសិទ្ធិទទួលបានការពន្យល់ច្បាស់លាស់អំពីច្បាប់ និងនីតិវិធី IRS ក្នុងសំណុំបែបបទពន្ធទាំងអស់ ការណែនាំ ការបោះពុម្ពផ្សាយ ការជូនដំណឹង និងសំបុត្រទាក់ទងគ្នា។ ពួកគេមានសិទ្ធិទទួលបានការជូនដំណឹងពីការសម្រេចចិត្តរបស់ IRS អំពីគណនីពន្ធរបស់ពួកគេ និងដើម្បីទទួលបានការពន្យល់ច្បាស់លាស់ពីលទ្ធផល។

### ២. សិទ្ធិទទួលបានសេវាកម្មដែលមានគុណភាព

អ្នកបង់ពន្ធមានសិទ្ធិទទួលបានជំនួយរហ័សទាន់ចិត្ត សុភាពរាបសា ប្រកបដោយវិជ្ជាជីវៈក្នុងការទំនាក់ទំនងជាមួយ IRS ដើម្បីឱ្យគេនិយាយមកកាន់ខ្លួនតាមរបៀបដែលពួកគេអាចងាយយល់ ទទួលបានការប្រាស្រ័យទាក់ទងច្បាស់លាស់ និងងាយយល់ពី IRS ហើយនិយាយជាមួយអ្នកត្រួតពិនិត្យអំពីសេវាកម្មដែលមិនល្អគ្រប់គ្រាន់។

### ៣. សិទ្ធិបង់មិនលើសពីចំនួនទឹកប្រាក់ពន្ធត្រឹមត្រូវ

អ្នកបង់ពន្ធមានសិទ្ធិបង់តែចំនួនពន្ធត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ រួមមានការប្រាក់ និងការពិន័យ ហើយដើម្បីឱ្យ IRS អនុវត្តរាល់ការបង់ពន្ធឱ្យបានត្រឹមត្រូវ។

### ៤. សិទ្ធិជំទាស់នឹងជំហររបស់ IRS ហើយដើម្បីឱ្យគេស្តាប់ឮ

អ្នកបង់ពន្ធមានសិទ្ធិក្នុងការលើកឡើងនូវការជំទាស់ និងផ្តល់ឯកសារបន្ថែមដើម្បីឆ្លើយតបទៅនឹងការសម្រេចជាផ្លូវការរបស់ IRS ឬការសម្រេចដែលបានដាក់ស្នើ ដើម្បីរំពឹងថា IRS នឹងពិចារណាលើការជំទាស់ និងការដាក់ឯកសាររបស់ពួកគេឱ្យបានទាន់ពេលវេលា រហ័សទាន់ចិត្ត ហើយយុត្តិធម៌ និងទទួលបានការឆ្លើយតបប្រសិនបើ IRS មិនយល់ស្របនឹងជំហររបស់ពួកគេ។

### ៥. សិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចរបស់ IRS នៅក្នុងវេទិកាឯករាជ្យមួយ

អ្នកបង់ពន្ធមានសិទ្ធិទទួលបានបណ្តឹងឧទ្ធរណ៍រដ្ឋបាលដែលយុត្តិធម៌ និងមិនលំអៀងនៃសេចក្តីសម្រេចរបស់ IRS រួមទាំងការពិន័យជាច្រើន ហើយមានសិទ្ធិទទួលបានការឆ្លើយតបជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងសេចក្តីសម្រេចរបស់ Office of Appeals (ការិយាល័យឧទ្ធរណ៍)។ ជាទូទៅ អ្នកបង់ពន្ធមានសិទ្ធិលើកយករឿងក្តីរបស់ខ្លួនទៅតុលាការ។

### ៦. សិទ្ធិទទួលបានដំណឹងអំពីការសម្រេចចុងក្រោយ

អ្នកបង់ពន្ធមានសិទ្ធិដើម្បីដឹងអំពីចំនួនពេលអតិបរមាដែលពួកគេមានដើម្បីជំទាស់នឹងជំហររបស់ IRS ក៏ដូចជាចំនួនពេលអតិបរមាដែល IRS មាន ដើម្បីធ្វើសវនកម្មនៅឆ្នាំជាប់ពន្ធជាក់លាក់ ឬប្រមូលបំណុលពន្ធ។ អ្នកបង់ពន្ធមានសិទ្ធិដើម្បីដឹងពីពេលដែល IRS បានបញ្ចប់សវនកម្ម។

### ៧. សិទ្ធិរក្សាភាពឯកជន

អ្នកបង់ពន្ធមានសិទ្ធិរំពឹងថារាល់ការសាកសួរ ការពិនិត្យ ឬការអនុវត្តសេចក្តីសម្រេចណាមួយរបស់ IRS នឹងអនុលោមតាមច្បាប់ និងមិនមានការរំលោភបំពានច្រើនជាងអ្វីដែលចាំបាច់ ហើយនឹងគោរពសិទ្ធិនីតិវិធីទាំងអស់ រួមមានកិច្ចការពារការឆែកឆេរ និងការរឹបអូស ហើយកន្លែងណាដែលអាចអនុវត្តបាន នឹងផ្តល់នីតិវិធីជំនំជម្រះក្តីស្តីពីការប្រមូលពន្ធ។

### ៨. សិទ្ធិរក្សាការសម្ងាត់

អ្នកបង់ពន្ធមានសិទ្ធិរំពឹងថារាល់ព័ត៌មានដែលពួកគេផ្តល់ទៅ IRS នឹងមិនត្រូវបានបញ្ចេញឱ្យគេដឹង លើកលែងតែមានការអនុញ្ញាតពីអ្នកបង់ពន្ធ ឬដោយច្បាប់។ អ្នកបង់ពន្ធមានសិទ្ធិរំពឹងថាបណ្តឹងសមស្របនឹងត្រូវបានធ្វើឡើងប្រឆាំងនឹងនិយោជិត អ្នករៀបចំឯកសារប្រកាសពន្ធ និងអ្នកផ្សេងទៀតដែលប្រើប្រាស់ ឬបញ្ចេញព័ត៌មានអំពីការប្រកាសពន្ធរបស់អ្នកបង់ពន្ធដោយមិនត្រឹមត្រូវ។

### ៩. សិទ្ធិទទួលបានអ្នកតំណាង

អ្នកបង់ពន្ធមានសិទ្ធិទទួលបានអ្នកតំណាងដែលមានការអនុញ្ញាតតាមជម្រើសរបស់ពួកគេ ដើម្បីតំណាងឱ្យពួកគេក្នុងការដោះស្រាយជាមួយ IRS។ អ្នកបង់ពន្ធមានសិទ្ធិស្វែងរកជំនួយពី Low Income Taxpayer Clinic (គ្លីនិកអ្នកបង់ពន្ធដែលមានប្រាក់ចំណូលទាប) ប្រសិនបើពួកគេមិនមានលទ្ធភាពជួលអ្នកតំណាង។

### ១០. សិទ្ធិទទួលបានប្រព័ន្ធពន្ធត្រឹមត្រូវ និងយុត្តិធម៌

អ្នកបង់ពន្ធមានសិទ្ធិរំពឹងថាប្រព័ន្ធពន្ធនឹងពិចារណាលើអង្គហេតុ និងកាលៈទេសៈដែលអាចប៉ះពាល់ដល់បំណុលជាមូលដ្ឋាន សមត្ថភាពក្នុងការបង់ប្រាក់ ឬសមត្ថភាពក្នុងការផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលា។ អ្នកបង់ពន្ធមានសិទ្ធិទទួលបានជំនួយពី Taxpayer Advocate Service (សេវាកម្មគាំទ្រអ្នកបង់ពន្ធ) ប្រសិនបើពួកគេជួបប្រទះនឹងការលំបាកផ្នែកហិរញ្ញវត្ថុ ឬប្រសិនបើ IRS មិនបានដោះស្រាយបញ្ហាពន្ធរបស់ពួកគេឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាតាមរយៈបណ្តាញធម្មតា។

---

**បេសកកម្មរបស់ IRS**

ដើម្បីផ្តល់ជូនសេវាកម្មដែលមានគុណភាពខ្ពស់ដល់អ្នកបង់ពន្ធរបស់សហរដ្ឋអាមេរិក ដោយជួយពួកគេឱ្យបានយល់ដឹង និងបំពេញនូវទំនួលខុសត្រូវខាងពន្ធរបស់ពួកគេ ហើយអនុវត្តច្បាប់ប្រកបដោយភាពសុចរិត និងយុត្តិធម៌ដល់មនុស្សទាំងអស់។

Publication 1 (KM) (Rev. 9-2017) Catalog Number 74800U Department of the Treasury **Internal Revenue Service** IRS.gov

# ការពិនិត្យ ការប្ដឹងឧទ្ធរណ៍ ការប្រមូលពន្ធ និងប្រាក់បង្វិលសងវិញ

## ការពិនិត្យ ( សវនកម្ម )

យើងទទួលយកការប្រកាសពន្ធរបស់អ្នកបង់ពន្ធ ដូចដែលបានដាក់។ ប្រសិនបើយើងសាកសួរអំពីការប្រកាសពន្ធរបស់អ្នក ឬជ្រើសរើសវាដើម្បី ពិនិត្យ នេះមិនមានន័យថាអ្នកជាមនុស្សមិនស្មោះត្រង់នោះទេ។ ការសាកសួរ ឬការពិនិត្យអាច ឬមិនអាចនាំឱ្យមានបង់ពន្ធបន្ថែម។ យើង អាចបិទករណីរបស់អ្នកដោយគ្មានការផ្លាស់ប្ដូរ ឬអ្នកអាចទទួលបាន ប្រាក់បង្វិលសងវិញ។

ដំណើរការនៃការជ្រើសរើសការប្រកាសពន្ធដើម្បីពិនិត្យ ធម្មតាចាប់ផ្ដើម តាមវិធីមួយ ក្នុងចំណោមវិធីពីរ។ ដំបូង យើងប្រើកម្មវិធីកុំព្យូទ័រដើម្បី កំណត់អត្តសញ្ញាណការប្រកាសពន្ធដែលអាចមានចំនួនមិនត្រឹមត្រូវ។ កម្មវិធីទាំងនេះអាចផ្អែកលើព័ត៌មានការប្រកាសពន្ធ ដូចជាសំណុំបែបបទ លេខ១០៩៩ ( Forms 1099 ) និង W-2 លើការសិក្សានៃការពិនិត្យ កន្លងមក ឬលើបញ្ហាមួយចំនួនដែលបានកំណត់ដោយគម្រោងការ អនុលោមតាមច្បាប់។ ទីពីរ យើងប្រើព័ត៌មានពីប្រភពខាងក្រៅដែល បង្ហាញថាការប្រកាសពន្ធអាចមានចំនួនមិនត្រឹមត្រូវ។ ប្រភពទាំងនេះ អាចរាប់បញ្ចូលទាំងសារព័ត៌មាន កំណត់ត្រាសាធារណៈ និងបុគ្គល ផ្ទាល់។ ប្រសិនបើយើងកំណត់ថាព័ត៌មានមានភាពត្រឹមត្រូវ និងអាច ទុកចិត្តបាន យើងអាចប្រើវាដើម្បីជ្រើសរើសការប្រកាសពន្ធណាមួយ សម្រាប់ការពិនិត្យ។

ការបោះពុម្ពផ្សាយលេខ៥៥៦ ( Publication 556 ), ការពិនិត្យលើ ការប្រកាសពន្ធ ( Examination of Returns ), សិទ្ធិបណ្ដឹងឧទ្ធរណ៍ ( Appeal Rights ) និងបណ្ដឹងទាមទារប្រាក់បង្វិលសងវិញ ( Claims for Refund ) ពន្យល់អំពីវិធាន និងនីតិវិធីដែលយើងអនុវត្តក្នុងការពិនិត្យ ។ ផ្នែកខាងក្រោមនេះ ផ្ដល់នូវទិដ្ឋភាពទូទៅពីរបៀបដែលយើងធ្វើការ ពិនិត្យ។

## តាមសំបុត្រ

យើងគ្រប់គ្រងការពិនិត្យ និងការសាកសួរជាច្រើនតាមតាមសំបុត្រ។ យើងនឹងផ្ញើលិខិតមួយច្បាប់ទៅអ្នក ដោយស្នើសុំព័ត៌មានបន្ថែម ឬ ហេតុផលដែលយើងជឿជាក់ថាវាអាចចាំបាច់ដើម្បីផ្លាស់ប្ដូរការប្រកាស ពន្ធរបស់អ្នក។ អ្នកអាចឆ្លើយតបតាមលិខិត ឬអ្នកអាចស្នើសុំកិច្ច សម្ភាសន៍ផ្ទាល់ខ្លួនជាមួយអ្នកពិនិត្យម្នាក់។ ប្រសិនបើអ្នកផ្ញើមកយើង នូវព័ត៌មានដែលបានស្នើសុំ ឬផ្ដល់នូវការពន្យល់ យើងអាច ឬមិនអាច យល់ព្រមជាមួយអ្នក ហើយយើងនឹងពន្យល់ពីមូលហេតុនៃការផ្លាស់ប្ដូរ ណាមួយ។ សូមកុំស្ទាក់ស្ទើរក្នុងការសរសេរមកយើង អំពីអ្វីមួយដែល អ្នកមិនយល់។

## តាមកិច្ចសម្ភាសន៍

ប្រសិនបើយើងជូនដំណឹងអ្នក ថាយើងនឹងធ្វើការពិនិត្យរបស់អ្នក តាមរយៈកិច្ចសម្ភាសន៍ផ្ទាល់ខ្លួន ឬអ្នកស្នើសុំកិច្ចសម្ភាសន៍នោះ អ្នកមាន សិទ្ធិស្នើសុំឱ្យមានការពិនិត្យតាមពេលវេលា និងទីកន្លែងដែលសម ហេតុផលសម្រាប់អ្នក និង IRS។ ប្រសិនបើអ្នកពិនិត្យរបស់យើងស្នើសុំ ការផ្លាស់ប្ដូរណាមួយ ចំពោះការប្រកាសពន្ធរបស់អ្នក ពួកគេនឹងពន្យល់ពី មូលហេតុនៃការផ្លាស់ប្ដូរនោះ។ ប្រសិនបើអ្នកមិនយល់ស្របនឹងការផ្លាស់ ប្ដូរទាំងនេះទេ អ្នកអាចសុំជួបជាមួយអ្នកត្រួតត្រារបស់អ្នកពិនិត្យនោះ។

## ការពិនិត្យម្ដងទៀត

ប្រសិនបើយើងបានពិនិត្យការប្រកាសពន្ធរបស់អ្នកចំពោះរឿងដដែលៗ ក្នុងរយៈពេល២ឆ្នាំកន្លងមក ហើយមិនបានស្នើសុំផ្លាស់ប្ដូរបំណុលពន្ធ របស់អ្នកទេ សូមទាក់ទងមកយើងឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យយើងអាចដឹងថាតើយើងគួរតែបញ្ឈប់ការពិនិត្យនោះឬអត់។

## បណ្ដឹងឧទ្ធរណ៍

ប្រសិនបើអ្នកមិនយល់ស្របនឹងការផ្លាស់ប្ដូរដែលបានដាក់ស្នើរបស់ អ្នកពិនិត្យទេ អ្នកអាចប្ដឹងឧទ្ធរណ៍ពួកគេទៅ Appeals Office of the IRS ( ការិយាល័យបណ្ដឹងឧទ្ធរណ៍របស់ IRS )។ ភាពខុសគ្នាភាគច្រើន អាចត្រូវបានដោះស្រាយដោយគ្មានការកាត់ក្ដីរបស់តុលាការដែល មានតម្លៃថ្លៃ និងចំណាយពេលច្រើន។ សិទ្ធិប្ដឹងឧទ្ធរណ៍របស់អ្នកត្រូវបាន ពន្យល់ជាលម្អិតទាំងនៅក្នុងការបោះពុម្ពផ្សាយលេខ៥ ( Publication 5 ), សិទ្ធិប្ដឹងឧទ្ធរណ៍របស់អ្នក និងរបៀបរៀបចំការតវ៉ា ប្រសិនបើអ្នក មិនយល់ស្រប ( Your Appeal Rights and How To Prepare a Protest If You Don't Agree ) និងនៅក្នុងការបោះពុម្ពផ្សាយលេខ៥៥៦ ( Publication 556 ), ការពិនិត្យប្រាក់បង្វិលសងវិញ ( Examination of Returns ), សិទ្ធិប្ដឹងឧទ្ធរណ៍ ( Appeal Rights ) និងបណ្ដឹងទាមទារ ប្រាក់បង្វិលសងវិញ ( Claims for Refund )។

ប្រសិនបើអ្នកមិនចង់ប្រើ Appeals Office ( ការិយាល័យបណ្ដឹង ឧទ្ធរណ៍ ) ឬមិនយល់ស្របនឹងការរកឃើញរបស់ការិយាល័យទេ អ្នក អាចលើកយករឿងក្ដីរបស់អ្នកទៅ U.S. Tax Court ( តុលាការពន្ធដារ សហរដ្ឋអាមេរិក ), U.S. Court of Federal Claims ( តុលាការបណ្ដឹង ទាមទារសំណងសហព័ន្ធ ) ឬ U.S. District Court ( តុលាការមូលដ្ឋាន សហរដ្ឋអាមេរិក ) នៅកន្លែងដែលអ្នករស់នៅ។ ប្រសិនបើអ្នកលើកយក រឿងក្ដីរបស់អ្នកទៅតុលាការ IRS នឹងមានបន្ទុកក្នុងការបង្ហាញអង្គហេតុ ជាក់លាក់ ប្រសិនបើអ្នករក្សាទុកកំណត់ត្រាគ្រប់គ្រាន់ដើម្បីបង្ហាញពី បំណុលពន្ធរបស់អ្នក បានសហការជាមួយ IRS និងបំពេញលក្ខខណ្ឌ ជាក់លាក់ផ្សេងទៀត។ ប្រសិនបើតុលាការយល់ស្របជាមួយអ្នកលើ បញ្ហាភាគច្រើនក្នុងករណីរបស់អ្នក ហើយឃើញថាជំហររបស់យើង មិនសមហេតុផលច្រើន អ្នកប្រហែលជាអាចទទួលបានមកវិញនូវការ ចំណាយរដ្ឋបាល និងការចំណាយលើបណ្ដឹងវិវាទមួយចំនួន។ អ្នកនឹង មិនមានសិទ្ធិទទួលបានមកវិញនូវការចំណាយទាំងនេះទេ លើកលែងតែ អ្នកបានព្យាយាមដោះស្រាយរឿងក្ដីរដ្ឋបាលរបស់អ្នក រួមទាំងការឆ្លងកាត់ ប្រព័ន្ធបណ្ដឹងឧទ្ធរណ៍ ហើយអ្នកបានផ្ដល់ឱ្យយើងនូវព័ត៌មានដែល ចាំបាច់ដើម្បីដោះស្រាយរឿងក្ដី។

## ការប្រមូលពន្ធ

ការបោះពុម្ពផ្សាយលេខ៥៩៤ ( Publication 594 ), ដំណើរការនៃការ ប្រមូលពន្ធ IRS ( IRS Collection Process ) ពន្យល់អំពីសិទ្ធិ និង ទំនួលខុសត្រូវរបស់អ្នកទាក់ទងនឹងការបង់ពន្ធសហព័ន្ធ។ វាពិពណ៌នា អំពី៖

- អ្វីដែលត្រូវធ្វើនៅពេលអ្នកជំពាក់ពន្ធ។ វាពិពណ៌នាអំពីអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកទទួលបានវិក្កយបត្រពន្ធ និងអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នក គិតថាវិក្កយបត្រពន្ធរបស់អ្នកខុស។ វារួមបញ្ចូលទាំងការបង់រំលស់ ការ ពន្យារពេលវិធានការប្រមូលពន្ធ និងការដាក់ស្នើការសម្របសម្រួល។
- វិធានការប្រមូលពន្ធរបស់ IRS។ វាគ្របដណ្ដប់លើសិទ្ធិឃាត់ទុក ការ ដោះលែងសិទ្ធិឃាត់ទុក ការយកពន្ធ ការដោះលែងពន្ធ ការរឹបអូស និង ការលក់ ហើយនិងការដោះលែងទ្រព្យសម្បត្តិ។
- ការបញ្ជាក់របស់ IRS ទៅ State Department ( នាយកដ្ឋានរដ្ឋ ) អំពី បំណុលពន្ធដែលមិនបានបំពេញកាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរ ដែលជាទូទៅនឹង បណ្ដាលឱ្យមានការបដិសេធការដាក់ពាក្យសុំលិខិតឆ្លងដែន ហើយអាច នាំមកនូវការឱ្យដកហូតលិខិតឆ្លងដែនទៀតផង។

សិទ្ធិប្ដឹងឧទ្ធរណ៍អំពីការប្រមូលពន្ធរបស់អ្នក ត្រូវបានពន្យល់ជាលម្អិត នៅក្នុងការបោះពុម្ពផ្សាយលេខ១៦៦០ ( Publication 1660 ) សិទ្ធិប្ដឹង ឧទ្ធរណ៍អំពីការប្រមូលពន្ធ ( Collection Appeal Rights )។

## ជំនួយសង្គ្រោះប្ដី/ប្រពន្ធដែលគ្មានកំហុស

ជាទូទៅ ទាំងអ្នក និងប្ដី/ប្រពន្ធរបស់អ្នក ម្នាក់ៗត្រូវទទួលខុសត្រូវលើការ បង់ចំនួនទឹកប្រាក់ពន្ធពេញ ការប្រាក់ និងការពិន័យដល់កំណត់នៅក្នុង ការប្រកាសពន្ធរួមគ្នារបស់អ្នក។ ទោះយ៉ាងណាក្ដី ប្រសិនបើអ្នកមាន លក្ខណៈគ្រប់គ្រាន់ដើម្បីទទួលជំនួយសង្គ្រោះសម្រាប់ប្ដី/ប្រពន្ធដែល គ្មានកំហុស អ្នកអាចត្រូវបានបន្ធូរបន្ថយពីផ្នែកខ្លះ ឬទាំងអស់នៃបំណុល រួមរបស់អ្នក។ ដើម្បីស្នើសុំការបន្ធូរបន្ថយ អ្នកត្រូវដាក់សំណុំបែបបទ លេខ៨៨៥៧ ( Form 8857 ), សំណើរសុំជំនួយសង្គ្រោះសម្រាប់ប្ដី/ ប្រពន្ធដែលគ្មានកំហុស ( Request for Innocent Spouse Relief )។ សម្រាប់ព័ត៌មានបន្ថែមអំពីជំនួយសង្គ្រោះសម្រាប់ប្ដី/ប្រពន្ធដែលគ្មាន កំហុស សូមមើលការបោះពុម្ពផ្សាយលេខ៩៧១ ( Publication 971 ), ជំនួយសង្គ្រោះសម្រាប់ប្ដី/ប្រពន្ធដែលគ្មានកំហុស ( Innocent Spouse Relief ) និងសំណុំបែបបទលេខ៨៨៥៧ ( Form 8857 )។

## ទំនាក់ទំនងរបស់ភាគីទីបីដែលមានសក្ដានុពល

ជាទូទៅ IRS នឹងទាក់ទងដោយផ្ទាល់ជាមួយអ្នក ឬអ្នកតំណាងដែល មានការអនុញ្ញាតត្រឹមត្រូវរបស់អ្នក។ ទោះយ៉ាងណាក្ដី ពេលខ្លះយើង និយាយជាមួយមនុស្សផ្សេងទៀត ប្រសិនបើយើងត្រូវការព័ត៌មានដែល អ្នកមិនអាចផ្ដល់ ឬដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលយើងបានទទួល។ ប្រសិនបើយើងទាក់ទងមនុស្សផ្សេងទៀត ដូចជាអ្នកជិតខាង ធនាគារ និយោជក ឬនិយោជិត ជាទូទៅ យើងនឹងត្រូវប្រាប់ពួកគេនូវព័ត៌មានដ៏ កំណត់ ដូចជាឈ្មោះរបស់អ្នក។ ច្បាប់ហាមឃាត់យើងមិនឱ្យបញ្ចេញ ព័ត៌មានលើសពីអ្វីដែលចាំបាច់ ដើម្បីទទួលបាន ឬផ្ទៀងផ្ទាត់ព័ត៌មាន ដែលយើងកំពុងស្វែងរក។ ការចាំបាច់របស់យើងដើម្បីទាក់ទងមនុស្ស ផ្សេងទៀតអាចបន្ត ដរាបណាមានសកម្មភាពនៅក្នុងករណីរបស់អ្នក ។ ប្រសិនបើយើងទាក់ទងមនុស្សផ្សេងទៀត អ្នកមានសិទ្ធិស្នើសុំបញ្ជី ឈ្មោះអ្នកដែលយើងបានទាក់ទង។ ការស្នើសុំរបស់អ្នកអាចធ្វើឡើង តាមទូរស័ព្ទ ជាលាយលក្ខណ៍អក្សរ ឬក្នុងអំឡុងពេលកិច្ចសម្ភាសន៍ ផ្ទាល់ខ្លួន។

## ប្រាក់បង្វិលសងវិញ

អ្នកអាចដាក់ពាក្យបណ្ដឹងទាមទារប្រាក់បង្វិលសងវិញ ប្រសិនបើអ្នក គិតថាអ្នកបានបង់ពន្ធច្រើនពេក។ ជាទូទៅ អ្នកត្រូវតែដាក់ពាក្យបណ្ដឹង ទាមទារក្នុងរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃដែលអ្នកបានដាក់ការប្រកាស ពន្ធដើមរបស់អ្នក ឬ២ឆ្នាំគិតចាប់ពីថ្ងៃដែលអ្នកបានបង់ពន្ធ គឺមួយណា ដែលចុងក្រោយគេ។ ជាទូទៅ ច្បាប់ផ្ដល់សម្រាប់ការប្រាក់លើប្រាក់បង្វិល សងវិញរបស់អ្នក ប្រសិនបើវាមិនបានបង់ក្នុងរយៈពេល៤៥ថ្ងៃ គិតចាប់ពី ថ្ងៃដែលអ្នកបានដាក់ការប្រកាសពន្ធ ឬទាមទារប្រាក់បង្វិលសងវិញរបស់ អ្នក។ ការបោះពុម្ពផ្សាយលេខ៥៥៦ ( Publication 556 ), ការពិនិត្យលើ ការប្រកាសពន្ធ ( Examination of Returns ), សិទ្ធិបណ្ដឹងឧទ្ធរណ៍ ( Appeal Rights ) និងបណ្ដឹងទាមទារប្រាក់បង្វិលសងវិញ ( Claims for Refund ) មានព័ត៌មានបន្ថែមអំពីប្រាក់បង្វិលសងវិញ។

ប្រសិនបើអ្នកដល់កាលកំណត់នឹងទទួលបានប្រាក់បង្វិលសងវិញ ក៏ប៉ុន្តែ អ្នកមិនបានដាក់ឯកសារប្រកាសពន្ធ ជាទូទៅ អ្នកត្រូវដាក់ឯកសារ ប្រកាសពន្ធរបស់អ្នកក្នុងរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃកំណត់ដែលអ្នក នឹងទទួលបានប្រាក់បង្វិលសងវិញ (រួមទាំងការពន្យារពេល ) ដើម្បី ទទួលបានប្រាក់បង្វិលសងវិញនេះ។

## Taxpayer Advocate Service ( សេវាកម្មគាំទ្រអ្នកបង់ពន្ធ )

TAS គឺជាអង្គការ ឯករាជ្យ មួយមាននៅក្នុង IRS ដែលអាចជួយការ ពារសិទ្ធិអ្នកបង់ពន្ធរបស់អ្នក។ យើងអាចផ្ដល់ជំនួយជូនអ្នក ប្រសិនបើ បញ្ហាពន្ធរបស់អ្នកបង្កការលំបាក ឬអ្នកបានព្យាយាម ក៏ប៉ុន្តែអ្នកមិនអាច ដោះស្រាយបញ្ហារបស់អ្នកជាមួយ IRS។ ប្រសិនបើអ្នកមានលក្ខណៈ គ្រប់គ្រាន់សម្រាប់ជំនួយរបស់យើងដែលឥតគិតថ្លៃជានិច្ច យើងនឹង ធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីជួយអ្នក។ សូមចូលមើល www.taxpayeradvocate.irs.gov ឬហៅទូរស័ព្ទលេខ 1-877-777-4778។

## ព័ត៌មានអំពីពន្ធដារ

IRS ផ្ដល់ជូនប្រភពដូចខាងក្រោមសម្រាប់សំណុំបែបបទ ការបោះពុម្ព ផ្សាយ និងព័ត៌មានបន្ថែម។

- ***សំណួរអំពីពន្ធ៖*** 1-800-829-1040 ( 1-800-829-4059 សម្រាប់ TTY/TDD )
- ***សំណុំបែបបទ ការបោះពុម្ពផ្សាយ៖*** 1-800-829-3676 ( 1-800-829-4059 សម្រាប់ TTY/TDD )
- ***អ៊ីនធើណិត៖*** *www.irs.gov*
- ***Small Business Ombudsman (ភ្នាក់ងារស៊ើបអង្កេតបណ្ដឹងតវ៉ាអាជីវកម្មខ្នាតតូច)៖*** អង្គភាពអាជីវកម្មខ្នាតតូចអាចចូលរួមក្នុង ដំណើរការនិយតកម្ម និងផ្ដល់យោបល់លើសកម្មភាពអនុវត្តរបស់ IRS ដោយហៅទូរស័ព្ទលេខ 1-888-REG-FAIR។
- ***Treasury Inspector General for Tax Administration ( អធិការរតនាគារសម្រាប់រដ្ឋបាលពន្ធដារ)៖*** អ្នកអាចរាយការណ៍ ដោយសម្ងាត់អំពីការប្រព្រឹត្តពុំត្រឹមត្រូវ ការខ្ជះខ្ជាយ ការលួចបន្លំ ឬការរំលោភបំពានដោយនិយោជិត IRS ដោយហៅទូរស័ព្ទលេខ 1-800-366-4484 ( 1-800-877-8339សម្រាប់ TTY/TDD )។ អ្នក អាចនៅតែរក្សាភាពអនាមិក។